ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ៧០ ក.យ/២០២៣

# សេចក្ដីសម្រេច
# ស្ដីពី
# ការកែសម្រួលសមាសភាពនៃ
# គណៈកម្មការជាតិដោះលែង
# ដោយមានលក្ខខណ្ឌ

២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :៧០.កយ.សសរ./២៣

# សេចក្ដីសម្រេច
# ស្ដីពី
# ការកែសម្រួលសមាសភាព
# នៃគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ០៩០ កយ.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ
- បានឃើញសេចក្ដីសម្រេចលេខ ១៦ កយ.សសរ/២១ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ស្ដីពីសមាសភាព និងការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ ដែលហៅកាត់ថា "**គ.ដ.ល.**" ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | **គីម សន្តិភាព** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ប្រធាន |
| ២-ឯកឧត្តម | **ឆែម សាវុធ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឯកឧត្តម | **យឹម សារី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |



មហាវិថីសម្ដេចសុធារស.ខណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

| | | | |
|---|---|---|---|
| ៤-ឯកឧត្តម | **ជាម សត្យា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទោសព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៥-ឯកឧត្តម | **ឈុន សារណាត** | អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦-ឯកឧត្តម | **នុត សវនា** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន ពន្ធនាគារនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៧-លោកជំទាវ | **សុន សុខាលីដា** | អគ្គនាយករងនៃអគ្គនាយកដ្ឋាន កិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ | សមាជិកា |
| ៨-លោក | **លី សុផាណា** | ប្រធាននាយកដ្ឋានស្រាវជ្រាវ និងស៊ើបអង្កេត នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៩-លោក | **ឃាត វិសាលរតនៈ** | ប្រធាននាយកដ្ឋានកិច្ចការអនុវត្តទោស និងដោះលែងដោយមានលក្ខខណ្ឌ នៃក្រសួងយុត្តិធម៌ | សមាជិក។ |

**ប្រការ២**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣**.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ១៥កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ